ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកុម្ភៈ ឆ្នាំ២០១៥

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមលោកស្រីអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។



ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានសំដែងអំណរសារទរជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ និងជម្រុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៥។

ក្នុងខែកុម្ភៈ ឆ្នាំ២០១៥នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣២៣ ០៩៤ លានរៀល (គិតជាដុល្លារប្រមាណ ៨០,៧៧ លានដុល្លារ)។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធប្រចាំខែកុម្ភៈ ដូចគ្នាឆ្នាំ២០១៤ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ នេះមានការកើនឡើងស្មើនឹង ២៥,១១%។

ក្នុងរយៈពេលពីរខែដើមឆ្នាំ២០១៥ ចំណូលពន្ធ-អាករសរុបមានចំនួនស្មើនឹង ១៤,២ % នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

ក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៤ និងឆ្នាំ២០១៥ ឃើញថា ក៏មានការកើនឡើងនូវចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗមួយចំនួន ដូចជា ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ៣០,៧% ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ១៥,៣% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ៩,០% និង អាករពិសេសមានការកើនឡើងប្រមាណ ២៦,២%។

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០១៤ និងឆ្នាំ២០១៥ ចំណូលពន្ធតាមសកម្មភាពអាជីវកម្មមានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន ÷ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ៣៤,៩% សេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ៣៧,៩% ទូរគមនាគមន៍កើនឡើងប្រមាណ ៤១,០% នីហរ័ណអាហរ័ណកើនឡើងប្រមាណ ២៦,៩% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ១២,១% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើង ប្រមាណ ៣១,៦% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ២១,៣% ផលិតថ្នាំជក់កើនឡើងប្រមាណ ១៣៥,៤% លក់សម្ភារៈការិយាល័យកើនឡើងប្រមាណ ៤២,១% លក់ភេសជ្ជៈកើនឡើងប្រមាណ ១១,៧% ផលិតយានយន្តកើនឡើងប្រមាណ ២៦១,៣% ផលិតម្ហូបអាហារកើនឡើងប្រមាណ ២៣,៥% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ២៤,៧% និងផលិតគ្រឿងចក្រកើនឡើងប្រមាណ ៧៩,១% ។



ក្នុងអង្គប្រជុំឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា ១-ពិនិត្យនិងពិភាក្សាលើរបាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែរបស់នាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌ។ ២-ការប្រកាសបង់ពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤។ ៣-ការប្រមូលពន្ធប៉ាតង់សម្រាប់ឆ្នាំ២០១៥។ ៤-ការពង្រឹងផ្នែកចាត់ចែងលិខិតប្រកាស ចំពោះសហគ្រាសស្ថិតក្នុងរបបស្វ័យប្រកាស។ ៥-ការពង្រឹងការធ្វើសវនកម្មពន្ធ។ ៦-ការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មីនិងការធ្វើបច្ចុប្បន្នភាពសហគ្រាស។ ៧-ការធ្វើបទបង្ហាញស្តីពីការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ពន្ធតាមគំរូថ្មី ដើម្បីធានាបាននូវភាពប្រសើរឡើង នូវតម្លាភាព ប្រសិទ្ធិភាព នៃការបង់ប្រាក់ពន្ធតាមរយៈប្រព័ន្ធធនាគារ។ ៨-បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឲ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនោះ ជាទិសដៅអនុវត្តបន្ត អគ្គនាយកដ្ឋានពន្ធដារនឹងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយកែទម្រង់ដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងនោះ ÷

- ពង្រឹងការប្រមូលពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៥ និងពន្ធលើប្រាក់ចំណេញ

- បន្តពង្រឹងការចុះបញ្ជីពន្ធដារ តាមប្រព័ន្ធថ្មី
- គ្រោងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំងអស់ ដែលបានចុះបញ្ជីពន្ធដារដាក់ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ
- ធ្វើបច្ចុប្បន្នភាពទិន្នន័យអចលនទ្រព្យទាំងអស់ដែលបានចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ដាក់ចូលក្នុងប្រព័ន្ធគ្រប់ គ្រងទិន្នន័យ (Database) របស់អគ្គនាយកដ្ឋានពន្ធដារ
- បន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌ពន្ធដារ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ក្នុងចំណោមធុរជនគ្រប់មជ្ឈដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រព័ន្ធពន្ធដារកម្ពុជា។



ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**អគ្គនាយកដ្ឋានពន្ធដារ**